# លិខិតរបស់គ្រីស្តទូតប៉ូល
# ផ្ញើជូនគ្រីស្តបរិស័ទនៅក្រុងអេភេសូ

## ពាក្យលំនាំ

### ក្រុងអេភេសូ

គ្រីស្តទូតប៉ូល ស្នាក់អាស្រ័យនៅក្រុងនេះ អស់រយៈពេលបីឆ្នាំ កាលលោកចេញទៅបំពេញបេសកកម្ម ប្រកាសដំណឹងល្អលើកទីបី (កក ១៨ ១៩,១-២០,១)។ ប្រជាជននៅក្រុងនោះភាគច្រើនមានអាជីវកម្ម ត្បាញសាច់កំណាត់ ហើយតែងតែគោរពបម្រើព្រះនាងអារទេមីស។ គេក៏ចូលចិត្តទស្សនវិជ្ជា ចូលចិត្តរិះគិតតាមព្រះប្រាជ្ញាញាណ ហើយធ្វើមន្តអាគមផ្សេងៗទៀតផង។

### ព្រះសហគមន៍នៅក្រុងអេភេសូ

នៅក្រុងអេភេសូមានជនជាតិយូដាមួយចំនួនធំ។ អ្នកខ្លះបានទទួលពិធីជ្រមុជទឹកតាមរបៀបលោកយ៉ូហាន-បាទីស្ត (កក ១៩,៣)។ នៅពេលគ្រីស្តទូតប៉ូលស្នាក់នៅក្រុងអេភេសូនេះ លោកមានសហការីជាច្រើន ហើយមានទំនាក់ទំនងជាមួយព្រះសហគមន៍ផ្សេងៗនៅស្រុកអាស៊ី តាមសហការី ឬដោយសរសេរលិខិតផ្ញើជូនព្រះសហគមន៍នានា (ភីលីព កូរិនថូ កាឡាទី ជាដើម)។

### លិខិតផ្ញើជូនគ្រីស្តបរិស័ទក្រុងអេភេសូ

តាមលិខិតនេះ គ្រីស្តទូតប៉ូលជាប់ឃុំឃាំង (៣,១) សហការីរបស់លោកមានឈ្មោះដូចសហការីនៅព្រះសហគមន៍កូឡូសដែរ (៦,២១-២២ ដូច កឡ ៤,៧-៨)។ ប៉ុន្តែបើប្រៀបធៀបនឹងលិខិតផ្ញើជូនព្រះសហគមន៍នៅកូឡូសសឲ្យឃើញថា មានលំនាំប្រហាក់ប្រហែលគ្នា។ ឧ. ក្នុង ខ ១១៥ មាន ខ ៧៥ ដូចក្នុងលិខិតកូឡូស។ ទោះបីគ្រីស្តទូតប៉ូលនៅក្រុងនោះបីឆ្នាំក្តី ក៏លោកហាក់ដូចជាមិនស្គាល់គ្រីស្តបរិស័ទក្រុងអេភេសូសោះ (១,១៥) គោលលទ្ធិជំនឿក៏ប្លែកពីលិខិតឯទៀតៗ។

ហេតុនេះហើយ បានជាអ្នកវិភាគជាច្រើនសន្និដ្ឋានថា មិនមែនគ្រីស្តទូតប៉ូលបានសរសេរលិខិតនេះទេ គឺកូនចៅលោកសរសេរទុក ជាលិខិតមួយផ្ញើជូនតៗគ្នា ទៅគ្រប់ព្រះសហគមន៍នានា នៅមជ្ឈិមបូព៌ាប្រទេស។ អ្នកនិពន្ធយកឈ្មោះគ្រីស្តទូតប៉ូល មកអះអាងតាមទំនៀមទម្លាប់នោះ។ អ្នកនិពន្ធមានបំណងចង់ជួយកែតម្រង់ជំនឿរបស់គ្រីស្តបរិស័ទព្រះសហគមន៍នានា នៅមជ្ឈិមបូព៌ាឲ្យបានសមស្របនឹងការប្រៀនប្រដៅរបស់គ្រីស្តទូតប៉ូល និងស្របតាមសភាពការណ៍ថ្មីគេរស់នៅ។ ទោះជាយ៉ាងណាក៏ដោយ ក៏ព្រះសហគមន៍រាប់បញ្ចូលលិខិតនេះ ក្នុងសាសនាបញ្ញត្តិរបស់ខ្លួនទុកជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ។

## គោលសំខាន់ៗ

អ្នកនិពន្ធរិះគិតអំពីគម្រោងការណ៍ដ៏លាក់កំបាំងរបស់ព្រះជាម្ចាស់ ដែលព្រះអង្គសព្វព្រះហឫទ័យសម្តែងដោយសារព្រះសហគមន៍។ ព្រះសហគមន៍ពិតជាព្រះកាយរបស់ព្រះគ្រីស្ត រីឯព្រះអង្គជាព្រះសិរសារបស់ព្រះសហគមន៍វិញ។ រីឯព្រះសហគមន៍នេះក៏ជាមហេសីរបស់ព្រះគ្រីស្ត។ ព្រះសហគមន៍នាំព្រះជន្មរបស់ព្រះអង្គមកឲ្យមនុស្សលោក។

លិខិតរបស់គ្រីស្តទូតប៉ូល
ផ្ញើជូនគ្រីស្តបរិស័ទនៅក្រុងអេភេសូ

## ពាក្យជម្រាបសួរ

[១]ខ្ញុំ ប៉ូល ព្រះជាម្ចាស់សព្វព្រះហឫទ័យតែងតាំង
១ ជាគ្រីស្តទូត* របស់ព្រះគ្រីស្ត*យេស៊ូ សូមជម្រាប
មកជនដ៏វិសុទ្ធ នៅក្រុងអេភេសូ[ក] ដែលជឿលើព្រះគ្រី
ស្តយេស៊ូ។ [២]សូមព្រះជាម្ចាស់ជាព្រះបិតារបស់យើង
និងព្រះអម្ចាស់យេស៊ូគ្រីស្តប្រោសប្រណី និងប្រទាន
សេចក្ដីសុខសាន្តដល់បងប្អូន។

## ពាក្យអរព្រះគុណ

[៣]សូមលើកតម្កើងព្រះជាម្ចាស់ ជាព្រះបិតារបស់
ព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់នៃយើង ដែលប្រោស
ប្រទានព្រះពរគ្រប់យ៉ាង ផ្នែកខាងវិញ្ញាណនៅស្ថាន
បរមសុខ*មកពីយើងក្នុងអង្គព្រះគ្រីស្ត។ [៤]ព្រះអង្គ
បានជ្រើសរើសយើងក្នុងអង្គព្រះគ្រីស្ត តាំងពីមុន
កំណើតពិភពលោកមកម្ល៉េះ ដើម្បីឲ្យយើងបាន
វិសុទ្ធ*និងឥតសៅហ្មង នៅចំពោះព្រះភក្ត្រព្រះអង្គ
ព្រោះ ព្រះអង្គមានព្រះហឫទ័យស្រឡាញ់យើង[ខ]។
[៥]ព្រះអង្គបានតម្រូវយើងទុកជាមុន ឲ្យធ្វើជាបុត្រធីតា
របស់ព្រះអង្គដោយសារព្រះយេស៊ូគ្រីស្ត ស្របនឹង
ព្រះបំណងដ៏សប្បុរសរបស់ព្រះអង្គ [៦]ដើម្បីឲ្យយើង
លើកតម្កើងសិរីរុងរឿង នៃព្រះហឫទ័យប្រោសប្រណី
ដែលទ្រង់បានប្រោសប្រទានមកយើង ក្នុងអង្គព្រះ
បុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ។ [៧]ដោយយើង
រួមក្នុងអង្គព្រះគ្រីស្តនេះ ព្រះជាម្ចាស់បានលោះយើង
ដោយព្រះលោហិតរបស់ព្រះអង្គ និងលើកលែង
ទោសឲ្យយើងបានរួចពីបាប តាមព្រះហឫទ័យ
ប្រោសប្រណីដ៏លើសលប់របស់ព្រះអង្គ។ [៨]ព្រះជា
ម្ចាស់ប្រោសប្រណីយើងយ៉ាងខ្លាំងបំផុត គឺទ្រង់
ប្រទានឲ្យយើងមានតម្រិះ និងប្រាជ្ញាដ៏វាងវៃគ្រប់យ៉ា
ង។ [៩]ព្រះអង្គបានប្រោសឲ្យយើងស្គាល់គម្រោងការ
ដ៏លាក់កំបាំង*នៃព្រះហឫទ័យរបស់ព្រះអង្គ គឺព្រះ
បំណងដ៏សប្បុរស ដែលទ្រង់បានសម្រេចទុកជាមុន
ដោយព្រះអង្គផ្ទាល់។ [១០]ព្រះអង្គចាត់ចែងគម្រោង
ការនេះឲ្យបានសម្រេច នៅគ្រាចុងក្រោយបំផុត គឺ
ប្រមូលអ្វីៗទាំងអស់ដែលនៅមេឃ និងនៅលើផែនដី
ឲ្យរួមគ្នានៅក្នុងអង្គព្រះគ្រីស្តជាម្ចាស់តែមួយ។ [១១]
ព្រះជាម្ចាស់ក៏តម្រូវយើងទុកជាមត៌កក្នុងអង្គព្រះគ្រី
ស្ត ស្របតាមផែនការរបស់ព្រះអង្គដែលសម្រេចគ្រប់
កិច្ចការទាំងអស់ តាមព្រះបំណងនៃព្រះហឫទ័យ
របស់ព្រះអង្គ [១២]ដើម្បីឲ្យយើងដែលរួមសង្ឃឹមក្នុងអង្គ
ព្រះគ្រីស្តមុនគេបង្អស់ កោតសរសើរសិរីរុងរឿងរបស់
ព្រះអង្គ។ [១៣]ដោយរួមក្នុងអង្គព្រះគ្រីស្ត បងប្អូនបាន
ទទួលព្រះបន្ទូលនៃសេចក្ដីពិតជាដំណឹងល្អដែលស
ង្គ្រោះបងប្អូន។ ក្នុងអង្គព្រះគ្រីស្តបងប្អូនក៏បានជឿ
ហើយបានទទួលសញ្ញាដៅសំគាល់ពីព្រះវិញ្ញាណដ៏
វិសុទ្ធ តាមព្រះបន្ទូលសន្យាដែរ។[១៤]ព្រះជាម្ចាស់
ប្រទានព្រះវិញ្ញាណនេះមកបញ្ជាំចិត្តយើងឲ្យដឹងថា
យើងនឹងទទួលមត៌កនៅពេលព្រះអង្គលោះប្រជារា
ស្ត្ររបស់ព្រះអង្គជាស្ពាពរដើម្បីឲ្យគេលើកតម្កើងសិរី
រុងរឿងរបស់ព្រះអង្គ។

## ពាក្យអធិដ្ឋាន

[១៥]ហេតុនេះបានជា តាំងពីពេលដែលខ្ញុំបានឮគេ
តំណាលអំពីជំនឿរបស់បងប្អូន រួមក្នុងអង្គព្រះអម្ចាស់
យេស៊ូ និងអំពីសេចក្ដីស្រឡាញ់របស់បងប្អូនចំពោះ
ជនដ៏វិសុទ្ធ*ទាំងអស់ [១៦]ខ្ញុំក៏អរព្រះគុណព្រះជាម្ចាស់
ឥតឈប់ឈរព្រោះតែបងប្អូន។ ពេលខ្ញុំអធិស្ឋាន*ខ្ញុំ
តែងតែនឹកគិតដល់បងប្អូនជានិច្ច [១៧]សូមឲ្យព្រះ
របស់ព្រះយេស៊ូគ្រីស្តជាអម្ចាស់នៃយើង គឺព្រះបិតា
ប្រកបដោយសិរីរុងរឿង ប្រទានព្រះវិញ្ញាណប្រកប
ដោយព្រះប្រាជ្ញាញាណ ដែលនឹងសម្ដែងឲ្យបងប្អូន

ស្គាល់ព្រះអង្គយ៉ាងច្បាស់។ ១៨សូមព្រះបិតាបំភ្លឺចិត្ត
គំនិតបងប្អូនឲ្យយល់ថា ដោយព្រះអង្គត្រាស់ហៅបង
ប្អូនបងប្អូនមានសេចក្ដីសង្ឃឹមយ៉ាងណា និងយល់ថា
ដោយបងប្អូនទទួលមត៌ក រួមជាមួយជនដ៏វិសុទ្ធ*បង
ប្អូននឹងមានសិរីរុងរឿង ដ៏ប្រសើរលើសលប់យ៉ាង
ណាដែរ!។១៩សូមទ្រង់ប្រទានឲ្យបងប្អូនយល់ទៀត
ថាឫទ្ធានុភាពដ៏អស្ចារ្យបំផុត ដែលព្រះអង្គសម្ដែងមក
ជាប្រយោជន៍ដល់យើង ជាអ្នកជឿមានទំហំធំធេង
យ៉ាងណា ស្របតាមមហិទ្ធិឫទ្ធិនៃព្រះចេស្ដាដ៏ខ្លាំងក្លា
ដែលទ្រង់បានសម្ដែងក្នុងអង្គព្រះគ្រីស្ដ។ ២០ព្រះអង្គ
បានសម្ដែងមហិទ្ធិឫទ្ធិនេះ ដោយប្រោសឲ្យព្រះគ្រីស្ដ
តើនឡើងពីចំណោមមនុស្សស្លាប់ និងគង់នៅខាង
ស្ដាំព្រះអង្គ នៅស្ថានបរមសុខ ២១ខ្ពស់ជាងវត្ថុសក្ដិ
សិទ្ធិគ្រប់យ៉ាង ខ្ពស់ជាងអ្វីៗដែលមានអំណាចខ្ពស់
ជាងអ្វីៗដែលមានឫទ្ធិបារមី ខ្ពស់ជាងម្ចាស់ទឹកម្ចាស់
ដី និងខ្ពស់លើសអ្វីៗដែលមានឈ្មោះ មិនត្រឹមតែនៅ
លោកនេះទេ គឺនៅលោកខាងមុខទៀតផង[គ]។២២ព្រះ
ជាម្ចាស់បានបង្ក្រាបអ្វីៗទាំងអស់ ឲ្យនៅក្រោមព្រះ
បាទារបស់ព្រះគ្រីស្ដ[ឃ] ព្រមទាំងប្រទានឲ្យព្រះអង្គ
គង់នៅលើអ្វីៗទាំងអស់ ធ្វើជាសិរសាលើព្រះសហ
គមន៍ ២៣ដែលជាព្រះកាយរបស់ព្រះអង្គ។ ព្រះសហ
គមន៍នេះបានពោរពេញ ដោយគ្រប់លក្ខណសម្បត្តិ
របស់ព្រះគ្រីស្ដ ហើយព្រះគ្រីស្ដផ្ទាល់ក៏បានពោរ
ពេញ ដោយគ្រប់លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់
ដែរ[ង]។

## គ្រីស្ដបរិស័ទរួចផុតពីសេចក្ដីស្លាប់

១ចំពោះបងប្អូន កាលពីមុន បងប្អូនស្លាប់ព្រោះតែ
២កំហុស និងអំពើបាបរបស់បងប្អូនរួចផុតទៅហើ
យ។ ២ពីដើម បងប្អូនរស់នៅតាមរបៀបលោកីយ៍នេះ
គឺតាមម្ចាស់ដែលឃាត់ឃាំងមនុស្ស[ច] មិនឲ្យទាក់ទង
ជាមួយនឹងព្រះជាម្ចាស់ ជាវិញ្ញាណ ដែលនៅតែមាន
ឥទ្ធិពល ក្នុងអស់អ្នកប្រឆាំងនឹងព្រះអង្គនាបច្ចុប្បន្ន
កាលនេះ។ ៣ពីដើម យើងទាំង អស់គ្នាក៏នៅក្នុង
ចំណោមពួកគេដែរ គឺយើងបណ្ដោយខ្លួន ទៅតាម
ចំណង់តណ្ហានៃលោកីយ៍នេះ យើងក៏ប្រព្រឹត្តអំពើផ្សេ
ងៗ ស្របតាមទំនើងចិត្តលោកីយ៍និងតាមគំនិតរបស់
យើង។ ពីកំណើតមក យើងជាមនុស្សដែលត្រូវតែ
ទទួលទោស[ឆ] ពីព្រះជាម្ចាស់ដូចមនុស្សឯទៀតៗដែរ
៤ក៏ប៉ុន្តែព្រះជាម្ចាស់ប្រកបដោយព្រះហឫទ័យ
អាណិតមេត្តា ដ៏ច្រើនពន់ប្រមាណនោះ ព្រះអង្គមាន
ព្រះហឫទ័យស្រឡាញ់យើងខ្លាំងបំផុត ៥គឺទោះបី
យើងស្លាប់ ដោយសារអំពើបាបរបស់យើងហើយក៏
ដោយ ក៏ព្រះអង្គបានប្រោសប្រទានឲ្យយើងមានជីវិត
រស់ រួមជាមួយព្រះគ្រីស្ដវិញដែរ។ ព្រះជាម្ចាស់បាន
សង្គ្រោះបងប្អូន មកពីព្រះអង្គមានព្រះហឫទ័យ
ប្រោសប្រណី។ ៦ព្រះអង្គបានប្រោសយើងឲ្យមាន
ជីវិតថ្មី រួមជាមួយព្រះគ្រីស្ដយេស៊ូ និងឲ្យយើងគ្រង
រាជ្យនៅស្ថានបរមសុខ រួមជាមួយព្រះអង្គដែរ។៧ព្រះ
អង្គបង្ហាញព្រះហឫទ័យសប្បុរស ចំពោះយើងក្នុង
អង្គព្រះគ្រីស្ដយេស៊ូដូច្នេះ ដើម្បីបង្ហាញឲ្យមនុស្ស
គ្រប់ជំនាន់ខាងមុខ ស្គាល់ព្រះហឫទ័យប្រោសប្រណី
ដ៏ប្រសើរលើសលប់បំផុតរបស់ព្រះអង្គ ៨ព្រះអង្គស
ង្គ្រោះបងប្អូន មកពីព្រះអង្គមានព្រះហឫទ័យប្រោស
ប្រណី ដោយសារបងប្អូនមានជំនឿ។ ការសង្គ្រោះ
មិនមែនមកពីបងប្អូនទេ គឺជាព្រះអំណោយទានរបស់
ព្រះជាម្ចាស់ ៩ហើយក៏មិនមែនមកពីមនុស្សប្រព្រឹត្ត
អំពើល្អដែរដើម្បីកុំឲ្យនរណាម្នាក់អួតខ្លួនបាន។ ១០
យើងជាស្នាព្រះហស្ដដែលព្រះជាម្ចាស់បានបង្កើត
មក ក្នុងអង្គព្រះគ្រីស្ដយេស៊ូ ដើម្បីឲ្យយើងប្រព្រឹត្ត
អំពើល្អដែលព្រះអង្គបានបម្រុងទុកជាមុនសម្រាប់ឲ្យ
យើងដើរតាម។

## ការរួបរួមគ្នាក្នុងអង្គព្រះគ្រីស្ដ

១១ដូច្នេះ សូមបងប្អូនចងចាំថា ពីដើមបងប្អូន
កើតមកជាសាសន៍ដទៃ ហើយសាសន៍យូដាដែល
ចាត់ទុកខ្លួនជា«*ពួកកាត់ស្បែក*» តែងហៅបងប្អូនថា
«*ពួកមិនកាត់ស្បែក*» ព្រោះគេសម្គាល់ទៅលើសញ្ញា

មួយដែលគេធ្វើលើរូបកាយ។ ១២កាលណោះបងប្អូនមិនរង់ចាំព្រះគ្រីស្ត គ្មានសិទ្ធិចូលជាតិអ៊ីស្រាអែល គ្មានទំនាក់ទំនងអ្វីនឹងសម្ព័ន្ធមេត្រី*[ជ] ដែលចងឡើងដោយព្រះបន្ទូលសន្យា របស់ព្រះជាម្ចាស់ទេបងប្អូនរស់នៅក្នុងលោកនេះ ដោយគ្មានសេចក្ដីសង្ឃឹម ហើយក៏គ្មានព្រះជាម្ចាស់ដែរ។ ១៣កាលពីមុនបងប្អូននៅឆ្ងាយមែន ក៏ប៉ុន្តែឥឡូវនេះ ដោយបងប្អូនរួមក្នុងអង្គព្រះយេស៊ូគ្រីស្ត បងប្អូនបានមកនៅជិតដោយសារព្រះលោហិតរបស់ព្រះគ្រីស្ត។ ១៤គឺព្រះគ្រីស្តហើយដែលជាសុខសាន្តរបស់យើង ព្រះអង្គបានប្រមូលសាសន៍ទាំងពីរ[ឈ] ឲ្យរួមគ្នាមកជាអង្គតែមួយ។ ដោយព្រះគ្រីស្តបូជាព្រះកាយព្រះអង្គ បានរំលំជញ្ជាំង ដែលធ្វើឲ្យសាសន៍ទាំងពីរដាច់ពីគ្នាហើយជាបច្ចាមិត្តនឹងគ្នា។ ១៥ព្រះអង្គបានលុបបំបាត់ធម្មវិន័យ*ដែលមានបញ្ញត្តិ និងបទបញ្ជាផ្សេងៗចោល ដើម្បីបង្រួបបង្រួមសាសន៍ទាំងពីរឲ្យទៅជាមនុស្សថ្មីតែមួយ ក្នុងព្រះអង្គផ្ទាល់ ព្រមទាំងនាំសន្តិភាពមកផង។ ១៦ដោយព្រះអង្គសោយទិវង្គតនៅលើឈើឆ្កាង ទ្រង់បានសម្រុះសម្រួលសាសន៍ទាំងពីរឲ្យរួមគ្នាជារូបកាយតែមួយ និងធ្វើឲ្យគេស្រុះស្រួលជាមួយព្រះជាម្ចាស់វិញ ទាំងកម្ចាត់ការស្អប់គ្នាចោលផង។ ១៧ព្រះអង្គបានយាងមក« _ទាំងនាំដំណឹងល្អ*អំពីសន្តិភាពមកឲ្យបងប្អូនដែលនៅឆ្ងាយ និង នាំសេចក្ដីសុខសាន្ត មកឲ្យអស់អ្នកដែលនៅជិតដែរ_ »[ញ]។ ១៨ដោយសារព្រះគ្រីស្តនេះហើយដែលយើងទាំងពីរសាសន៍មានផ្លូវចូលទៅរកព្រះបិតាដោយរួមក្នុងព្រះវិញ្ញាណតែមួយ។

១៩ហេតុនេះបងប្អូនលែងជាជនបរទេស ឬជាអាណិកជនទៀតហើយ គឺបងប្អូនជាជនរួមជាតិជាមួយជនដ៏វិសុទ្ធ* និងជាក្រុមគ្រួសាររបស់ព្រះជាម្ចាស់។ ២០ព្រះអង្គបានយកបងប្អូនចូលមកកសាងដោយមានក្រុមគ្រីស្តទូត* និងព្យាការី*ជាគ្រឹះ និងមានព្រះគ្រីស្តយេស៊ូផ្ទាល់ ជាថ្មដ៏សំខាន់។ ២១គឺព្រះគ្រីស្តហើយដែលធ្វើឲ្យសំណង់ទាំងមូលភ្ជាប់គ្នាយ៉ាងមាំ និងធ្វើឲ្យចម្រើនឡើងទៅជាព្រះវិហារ*ដ៏វិសុទ្ធមួយ រួមជាមួយព្រះអម្ចាស់។ ២២រីឯបងប្អូនក៏ដូច្នោះដែរ ដោយបងប្អូនរួមជាមួយព្រះអង្គ បងប្អូនបានផ្គុំគ្នាឡើង ធ្វើជាព្រះដំណាក់របស់ព្រះជាម្ចាស់ ក្នុងព្រះវិញ្ញាណ។

## ភារកិច្ចរបស់គ្រីស្តទូត

១ហេតុនេះហើយបានជាខ្ញុំ ប៉ូល ដែលជាប់ឃុំឃាំង ព្រោះតែព្រះគ្រីស្តយេស៊ូ ដើម្បីជាប្រយោជន៍ដល់បងប្អូនសាសន៍ដទៃ...។ ២បងប្អូនបានឮគេនិយាយអំពីមុខងារ ដែលព្រះជាម្ចាស់ប្រោសប្រណីឲ្យខ្ញុំបំពេញ ដើម្បីជាប្រយោជន៍ដល់បងប្អូន។ ៣ព្រះអង្គបានបង្ហាញគម្រោងការដ៏លាក់កំបាំង ឲ្យខ្ញុំស្គាល់ដូចខ្ញុំទើបនឹងសរសេរយ៉ាងខ្លី ខាងលើនេះស្រាប់។ ៤ពេលបងប្អូនអានសេចក្ដីនោះ បងប្អូនមុខជាដឹងថា ខ្ញុំយល់ច្បាស់ អំពីគម្រោងការដ៏លាក់កំបាំងរបស់ព្រះគ្រីស្ត។ ៥នៅជំនាន់ដើមមនុស្សម្នាពុំបានស្គាល់គម្រោងការនេះ ដូចព្រះជាម្ចាស់បានសម្តែងឲ្យក្រុមគ្រីស្តទូត*និងព្យាការី*ដ៏វិសុទ្ធ*របស់ព្រះអង្គ នាបច្ចុប្បន្នកាលស្គាល់ ដោយព្រះវិញ្ញាណនោះឡើយ ៦គឺថា ដោយសារដំណឹងល្អ*សាសន៍ដទៃមានសិទ្ធិចូលរួមទទួលមត៌ក មានសិទ្ធិចូលរួមក្នុងព្រះកាយតែមួយ និងមានសិទ្ធិទទួលព្រះពរតាមព្រះបន្ទូលសន្យារួមជាមួយសាសន៍អ៊ីស្រាអែលក្នុងអង្គព្រះគ្រីស្តយេស៊ូដែរ។ ៧ខ្ញុំបានទទួលមុខងារបម្រើដំណឹងល្អនេះតាមព្រះអំណោយទាននៃព្រះហឫទ័យ ប្រោសប្រណីរបស់ព្រះជាម្ចាស់មកលើរូបខ្ញុំ គឺជាព្រះអំណោយទានដែលព្រះអង្គប្រោសប្រទានមកខ្ញុំ ដោយឫទ្ធានុភាពដ៏ខ្លាំងពូកែរបស់ព្រះអង្គ។ ៨ទោះបីខ្ញុំមានឋានៈតូចជាងគេបំផុត ក្នុងចំណោមជនដ៏វិសុទ្ធ*ក្ដីក៏ព្រះជាម្ចាស់បានប្រោសប្រណីឲ្យខ្ញុំនាំដំណឹងល្អ ទៅប្រាប់សាសន៍ដទៃ អំពីព្រះជន្មដ៏បរិបូណ៌បំផុតរបស់ព្រះគ្រីស្ត[ដ] ដែលមនុស្សលោកគិតមិនដល់នោះដែរ។ ៩ព្រះ

ជាម្ចាស់ក៏ប្រោសប្រណី ឲ្យខ្ញុំបំភ្លឺមនុស្សទាំងអស់
ស្គាល់របៀបព្រះអង្គចាត់ចែងគម្រោងការ ដែលលាក់
ទុក តាំងពីអស់កល្បជានិច្ចរៀងមក ក្នុងព្រះជាម្ចាស់
ផ្ទាល់ ដែលបានបង្កើតអ្វីៗសព្វសារពើ។ ១០នៅពេល
នេះដោយសារព្រះសហគមន៍ វត្ថុសក្តិសិទ្ធិនិង
អំណាចនានានៅស្ថានលើ បានស្គាល់ព្រះប្រាជ្ញា
ញាណគ្រប់វិស័យរបស់ព្រះជាម្ចាស់ ១១តាមផែនការ
ដែលព្រះអង្គបានគ្រោងទុក តាំងពីអស់កល្បជានិច្ច
រៀងមក ហើយទ្រង់បានសម្រេចដោយសារព្រះគ្រីស្ត
យេស៊ូជាព្រះអម្ចាស់នៃយើង។ ១២ដោយរួមក្នុងអង្គ
ព្រះគ្រីស្ត យើងមានចិត្តអង់អាច និងមានផ្លូវចូលទៅ
កាន់ព្រះជាម្ចាស់ ដោយពឹងលើជំនឿរបស់គ្រីស្ត។
១៣ហេតុនេះ សូមបងប្អូនកុំធ្លាក់ទឹកចិត្ត ដោយខ្ញុំរង
ទុក្ខវេទនា ដើម្បីជាប្រយោជន៍ដល់បងប្អូននោះឡើយ
ទុក្ខវេទនាទាំងនេះជាសិរីរុងរឿងរបស់បងប្អូនវិញ
ទេ។

## ព្រះហឫទ័យស្រឡាញ់របស់ព្រះគ្រីស្ត

១៤ហេតុនេះហើយបានជា ខ្ញុំក្រាបថ្វាយបង្គំ[ប]ព្រះ
បិតា ១៥ដែលជាប្រភពនៃក្រុមគ្រួសារទាំងអស់ទាំង
នៅស្ថានបរមសុខ*ទាំងនៅផែនដី ១៦សូមព្រះអង្គ
មេត្តាប្រោសបងប្អូនឲ្យមានកម្លាំងមាំមួន ផ្នែក ខាង
ក្នុងជម្រៅចិត្ត[ឱ] ដោយព្រះវិញ្ញាណរបស់ព្រះអង្គតាម
សិរីរុងរឿងដ៏ប្រសើរបំផុតរបស់ព្រះអង្គ។ ១៧សូមព្រះ
គ្រីស្តគង់នៅក្នុងចិត្តបងប្អូន ដោយសារជំនឿ និង
សូមឲ្យបងប្អូនបានចាក់ឫសយ៉ាងមាំមួន ក្នុងសេចក្ដី
ស្រឡាញ់ ១៨ដើម្បីឲ្យបងប្អូនមានសមត្ថភាពអាច
យល់រួមជាមួយជនដ៏វិសុទ្ធ*ទាំងមូល នូវទទឹងប
ណ្ដោយ ជម្រៅ និងកម្ពស់ ១៩គឺឲ្យបងប្អូនស្គាល់ព្រះ
ហឫទ័យស្រឡាញ់របស់ព្រះគ្រីស្ត ដែលប្រសើរហួស
ពីការយល់ឃើញរបស់មនុស្ស ដើម្បីឲ្យបងប្អូនបាន
ពោរពេញដោយគ្រប់លក្ខណសម្បត្តិរបស់ព្រះជាម្ចា
ស់។

២០ព្រះជាម្ចាស់អាចធ្វើអ្វីៗទាំងអស់ ហួសពី
សេចក្ដីសុំនិងហួសពីអ្វីៗដែលយើងនឹកគិត ដោយ
សារឫទ្ធានុភាពរបស់ព្រះអង្គ ដែលបំពេញសកម្មភាព
នៅក្នុងយើង ២១សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះ
អង្គក្នុងព្រះសហគមន៍ និងក្នុងព្រះគ្រីស្តយេស៊ូ នៅ
គ្រប់ជំនាន់ អស់កល្បជាអង្វែងតរៀងទៅ។ អាម៉ែន។

## ការរួបរួមរបស់គ្រីស្តបរិស័ទ

១ហេតុនេះ ខ្ញុំដែលជាប់ឃុំឃាំង សូមដាស់តឿន
៤បងប្អូន ក្នុងព្រះនាមព្រះអម្ចាស់ថាដោយព្រះជា
ម្ចាស់បានត្រាស់ហៅបងប្អូន ចូររស់នៅ[ឈ]ឲ្យបានសម
រម្យនឹងការត្រាស់ហៅនោះទៅ។ ២ចូរបន្ទាបខ្លួន មាន
ចិត្តស្លូតបូត និងចេះអត់ធ្មត់ ព្រមទាំងទ្រាំទ្រគ្នាទៅ
វិញទៅមក ដោយសេចក្ដីស្រឡាញ់។ ៣ចូរយកចិត្ត
ទុកដាក់រក្សា ឯកភាពដែលមកពីព្រះវិញ្ញាណដោយ
យកសេចក្ដីសុខសាន្ត ធ្វើជាចំណងប្រាស្រ័យ
ទាក់ទងគ្នា។

៤ព្រះកាយមានតែមួយ ហើយព្រះវិញ្ញាណក៏មាន
តែមួយ ដូចព្រះជាម្ចាស់បានត្រាស់ហៅបងប្អូនឲ្យ
មានសេចក្ដីសង្ឃឹមតែមួយនោះដែរ។ ៥ព្រះអម្ចាស់
មានតែមួយ ជំនឿមានតែមួយ ពិធីជ្រមុជទឹក*មាន
តែមួយ។ ៦ព្រះជាម្ចាស់មានតែមួយព្រះអង្គជាព្រះ
បិតារបស់មនុស្សទាំងអស់ ព្រះអង្គខ្ពង់ខ្ពស់លើសអ្វីៗ
ទាំងអស់ ហើយព្រះអង្គធ្វើការដោយសារមនុស្សទាំង
អស់ និងសណ្ឋិតនៅក្នុងមនុស្សទាំងអស់។

៧ព្រះអង្គបានប្រោសប្រណីយើងម្នាក់ៗ តាមកំ
រិតព្រះអំណោយទាន ដែលព្រះគ្រីស្តប្រទានមកយើ
ង។ ៨ហេតុនេះហើយបានជាមានថ្លែងទុកថា៖«*ព្រះ
អង្គបានយាងឡើងទៅស្ថានខ្ពស់ ព្រះអង្គបានរំដោះ
ពួកជាប់ជាឈ្លើយនាំទៅជាមួយ ហើយព្រះអង្គ
ប្រទានព្រះអំណោយទានផ្សេងៗ ដល់មនុស្ស
លោក*»[ណ]។

៩ពាក្យថា "*យាងឡើងទៅ*" នោះ បានសេចក្ដី

ថាដូចម្ដេច? គឺបានសេចក្ដីថា ព្រះអង្គបានយាងចុះ
មកផែនដីដ៏ទាបនេះ[ត]ជាមុនសិន។ [១០]ព្រះអង្គដែល
បានយាងចុះមកនោះ ជាព្រះអង្គដែលបានយាង
ឡើងទៅទីដ៏ខ្ពស់បំផុតនៃស្ថានបរមសុខ* ដើម្បី
បំពេញអ្វីៗទាំងអស់។ [១១]គឺព្រះអង្គហើយដែលបាន
ប្រទានឲ្យអ្នកខ្លះមានមុខងារជាគ្រីស្ដទូត* ឲ្យអ្នកខ្លះ
ថ្លែងព្រះបន្ទូល អ្នកខ្លះប្រកាសដំណឹងល្អ* អ្នកខ្លះជា
អ្នកគង្វាល និងអ្នកខ្លះទៀតជាអ្នកបង្រៀន [១២]ដើម្បី
រៀបចំជនដ៏វិសុទ្ធឲ្យបំពេញមុខងារបម្រើ និងកសាង
ព្រះកាយរបស់ព្រះគ្រីស្ដឡើង [១៣]រហូតដល់យើង
ទាំងអស់រួមគ្នាមានជំនឿតែមួយ មានគំនិតតែមួយ
ក្នុងការស្គាល់ព្រះបុត្រារបស់ព្រះជាម្ចាស់ និងទៅជា
មនុស្សពេញវ័យឡើង ដល់កម្ពស់របស់ព្រះគ្រីស្ដ
ដែលបំពេញអ្វីៗទាំងអស់[ថ]។ [១៤]ដូច្នេះយើងមិនមែន
ជាកូនក្មេងដែលរេរា ត្រូវខ្យល់នៃគោលលទ្ធិនានា
ផាត់ចុះផាត់ឡើងនោះទៀតឡើយ ហើយក៏លែង
ចាញ់បោក ឬចាញ់កលល្បិចមនុស្សដែលពូកែនាំឲ្យ
វង្វេងនោះទៀតដែរ។

[១៥]ផ្ទុយទៅវិញ បើយើងប្រព្រឹត្តតាមសេចក្ដីពិត
ដោយចិត្តស្រឡាញ់ យើងនឹងបានចម្រើនឡើងគ្រប់វិ
ស័យទាំងអស់ឆ្ពោះទៅកាន់ព្រះគ្រីស្ដជាសិរសា [១៦]គឺ
ព្រះអង្គហើយដែលធ្វើឲ្យព្រះកាយទាំងមូលបានផ្គុំគ្នា
និងភ្ជាប់គ្នាឡើងយ៉ាងមាំ ដោយសារសន្លាក់ឆ្អឹងទាំង
ប៉ុន្មានដែលបម្រើព្រះកាយ តាមកម្រិតសមត្ថភាព
របស់សរីរាង្គនីមួយៗ ដើម្បីឲ្យព្រះកាយនោះចម្រើន
និងកសាងឡើង ក្នុងសេចក្ដីស្រឡាញ់។

## ជីវិតចាស់ និង ជីវិតថ្មី

[១៧]ដូច្នេះ ខ្ញុំសូមជម្រាបបងប្អូន និងបញ្ជាក់ក្នុង
ព្រះនាមព្រះអម្ចាស់ថា សូមកុំរស់នៅដូចសាសន៍
ដទៃ[ទ] ដែលប្រព្រឹត្តតាមប្រាជ្ញាដ៏ឥតប្រយោជន៍របស់
គេនោះទៀតឡើយ។ [១៨]គំនិតអ្នកទាំងនោះងងឹត
សូន្យសុង គេនៅឆ្ងាយពីព្រះជន្មរបស់ព្រះជាម្ចាស់
ព្រោះគេមិនស្គាល់ព្រះអង្គ[ធ] ហើយមានចិត្តរឹងរូស
ទៀតផង។ [១៩]ដោយពួកគេលែងដឹងខុសត្រូវ គេនាំ
គ្នាប្រាសចាកសីលធម៌ បណ្ដោយខ្លួនទៅប្រព្រឹត្តអំពើ
អបាយមុខគ្រប់យ៉ាងតាមតែចិត្តលោភលន់របស់គេ។

[២០]រីឯបងប្អូនវិញ បងប្អូនពុំបានទទួលការអប់រំ
អំពីព្រះគ្រីស្ដរបៀបនេះទេ។ [២១]ប្រសិនបើបងប្អូន
បានឮគេនិយាយអំពីព្រះយេស៊ូ ហើយប្រសិនបើបង
ប្អូនបានទទួលការអប់រំអំពីព្រះអង្គ ស្របតាមសេចក្ដី
ពិតដែលមកពីព្រះអង្គមែន [២២]បងប្អូនត្រូវតែលះបង់
កិរិយាមារយាទដែលបងប្អូនធ្លាប់កាន់ពីដើម គឺត្រូវ
ដោះជីវិតចាស់ដែលកំពុងតែវិនាស តាមបំណង
តណ្ហា បញ្ឆោតចិត្តនេះចោលទៅ។ [២៣]ត្រូវប្រែគំនិត
ប្រាជ្ញា និងវិញ្ញាណឲ្យបានថ្មីឡើង [២៤]ហើយត្រូវពាក់
ជីវិតថ្មីដ៏សុចរិត*និងដ៏វិសុទ្ធ* មកពីសេចក្ដីពិត ជា
ជីវិតដែលព្រះជាម្ចាស់បានបង្កើត ស្របតាមព្រះ
ហឫទ័យរបស់ព្រះអង្គ។

[២៥]ហេតុនេះ សូមបងប្អូនឈប់និយាយកុហកទៅ
*«ម្នាក់ៗត្រូវនិយាយតែសេចក្ដីពិត ទៅកាន់បងប្អូន
ឯទៀតៗ»*[ន] ដ្បិតយើងជាសរីរាង្គរបស់គ្នាទៅវិញទៅ
មក។ [២៦]ប្រសិនបើបងប្អូនខឹង សូមប្រយ័ត្នកុំប្រព្រឹត្ត
អំពើបាប»[ប] កុំទុកកំហឹងរហូតដល់ថ្ងៃលិចនោះឡើ
យ។ [២៧]កុំហុចឱកាសឲ្យមារ*មកល្បួងបងប្អូន។ [២៨]
អ្នកណាធ្លាប់លួច កុំលួចទៀត ផ្ទុយទៅវិញ ត្រូវខំ
ប្រឹងធ្វើការដោយចិត្តទៀងត្រង់ ដើម្បីយកផលទៅ
ជួយអ្នកដែលខ្វះខាត។ [២៩]កុំឲ្យមានពាក្យអាស្រូវ
ណាមួយ ចេញពីមាត់បងប្អូនឡើយ ផ្ទុយទៅវិញ ត្រូវ
និយាយតែពាក្យល្អដែលជួយកសាងជំនឿអ្នកដទៃ
ប្រសិនបើគេត្រូវការ ព្រមទាំងផ្ដល់ផលប្រយោជន៍
ដល់អ្នកស្ដាប់ផងដែរ។ [៣០]កុំធ្វើឲ្យព្រះវិញ្ញាណដ៏
វិសុទ្ធ*របស់ព្រះជាម្ចាស់ ព្រួយព្រះហឫទ័យសោះ
ឡើយ ដ្បិតព្រះអង្គបានដៅសញ្ញាសម្គាល់របស់ព្រះ
វិញ្ញាណមកលើបងប្អូន ទុកសម្រាប់ថ្ងៃដែលព្រះអង្គ

នឹងយាងមកលោះយើង។

៣១ សូមបងប្អូនកម្ចាត់ចិត្តជូរចត់ ចិត្តក្ដៅក្រហាយ
កំហឹងសម្រែកឡូឡា ពាក្យជេរប្រមាថ ព្រមទាំង
សេចក្ដីអាក្រក់គ្រប់បែបយ៉ាង ចេញពីចំណោមបង
ប្អូនទៅ។ ៣២ត្រូវមានចិត្តសប្បុរស និងចេះអាណិត
មេត្តាដល់គ្នាទៅវិញទៅមក។ ត្រូវប្រោសប្រណីគ្នា
ទៅវិញទៅមក ដូចព្រះជាម្ចាស់បានប្រោសប្រណីបង
ប្អូន ដោយសារព្រះគ្រីស្ដដែរ។

## របៀបរស់នៅក្នុងពន្លឺ

១ សូមបងប្អូនយកតម្រាប់តាមព្រះជាម្ចាស់ចុះព្រោះ
៥បងប្អូនជាបុត្រធីតា ដ៏ជាទីស្រឡាញ់របស់ព្រះអ
ង្គ។ ២ ចូររស់នៅដោយមានចិត្តស្រឡាញ់ដូចព្រះគ្រី
ស្ដបានស្រឡាញ់យើង ហើយបានបូជាព្រះជន្ម
សម្រាប់យើងទុកជាតង្វាយ ថ្វាយព្រះជាម្ចាស់ និង
ទុកជាយញ្ញបូជាដែលគាប់ព្រះហឫទ័យព្រះអង្គ[ផ]។
៣ដោយបងប្អូនជាជនដ៏វិសុទ្ធ* មិនត្រូវឲ្យមានឮ
និយាយអំពីការប្រាសចាកសីលធម៌ អបាយមុខគ្រប់
យ៉ាង ឬការលោភលន់ក្នុងចំណោមបងប្អូនសោះ
ឡើយ ៤ហើយក៏មិនត្រូវពោលពាក្យទ្រគោះបោះ
បោក ពាក្យឡេះឡោះ ឬពាក្យអាសអាភាសដែរ
ព្រោះពាក្យទាំងនេះមិនសមរម្យទេ ផ្ទុយទៅវិញត្រូវ
ពោលពាក្យអរព្រះគុណព្រះជាម្ចាស់។ ៥ចូរដឹងឲ្យ
ច្បាស់ថា អ្នកប្រាសចាកសីលធម៌អ្នកប្រព្រឹត្តអំពើ
អបាយមុខ និងអ្នកលោភលន់ដែលយកទ្រព្យសម្បត្តិ
ធ្វើជាព្រះ មិនអាចទទួលមត៌កក្នុងព្រះរាជ្យ*របស់
ព្រះគ្រីស្ដ និងរបស់ព្រះជាម្ចាស់បានជាដាច់ខាត។
៦ សូមកុំឲ្យនរណាម្នាក់បោកបញ្ឆោតបងប្អូន ដោយ
ពាក្យសំដីឥតខ្លឹមសារសោះឡើយ ព្រោះអំពើទាំង
នេះហើយ ដែលនាំឲ្យព្រះជាម្ចាស់ព្រះពិរោធនឹងពួក
អ្នកប្រឆាំងព្រះអង្គ។ ៧ដូច្នេះសូមកុំសេពគប់ជាមួយ
ពួកគេជាដាច់ខាត។

៨កាលពីដើមបងប្អូនងងឹតមែន ប៉ុន្តែឥឡូវនេះ
បងប្អូនជាពន្លឺ ដោយបានរួមជាមួយព្រះអម្ចាស់ ដូច្នេះ
ចូររស់នៅ ឲ្យសមជាមនុស្សដែលមានពន្លឺក្នុងខ្លួន[ព]
ទៅ។ ៩ផលនៃពន្លឺនោះ គឺសេចក្ដីសប្បុរសសេចក្ដី
សុចរិត និងសេចក្ដីពិតគ្រប់បែបយ៉ាង។ ១០ត្រូវរិះគិត
មើលឲ្យដឹងថា ការណាគាប់ព្រះហឫទ័យព្រះអម្ចាស់
១១ហើយមិនត្រូវចូលរួម ក្នុងការប្រព្រឹត្តអំពើឥតផល
ប្រយោជន៍ ដែលមកពីសេចក្ដីងងឹតនោះឡើយ សូវ
បើកមុខអំពើទាំងនោះឲ្យគេឃើញ។ ១២ចំពោះអំពើ
ណាដែលគេប្រព្រឹត្តដោយលួចលាក់ សូម្បីតែយក
មកនិយាយក៏គួរឲ្យខ្មាសណាស់ទៅហើយ។ ១៣ក៏
ប៉ុន្តែ កាលណាអំពើទាំងនោះបានបើកមុខហើយ វា
នឹងលេចចេញមកឲ្យគេឃើញច្បាស់ នៅក្រោមពន្លឺ
១៤ដ្បិត អំពើណាដែលលេចមកឲ្យគេឃើញហើយ
នោះ បានប្រែទៅជាពន្លឺ។ ហេតុនេះហើយបានជា
មានថ្លែងទុកមកថា៖ *«អ្នកដេកលក់អើយ ចូរភ្ញាក់
ឡើង ចូរក្រោកឡើងចេញពីចំណោមមនុស្សស្លាប់
ព្រះគ្រីស្ដនឹងភ្លឺចាំងមកលើអ្នក»*។

១៥ដូច្នេះ ចូរប្រុងប្រយ័ត្នអំពីរបៀបដែលបងប្អូន
រស់នៅឲ្យមែនទែន មិនត្រូវកាន់មារយាទ ដូចមនុស្ស
ឥតប្រាជ្ញាឡើយ គឺត្រូវកាន់មារយាទដូចមនុស្សមាន
ប្រាជ្ញាវិញ។ ១៦ត្រូវចេះប្រើប្រាស់ពេលវេលា ដ្បិត
សម័យនេះអាក្រក់ណាស់។ ១៧ហេតុនេះមិនត្រូវធ្វើ
ជាមនុស្សឥតគំនិតឡើយ តែត្រូវរិះគិតឲ្យយល់ព្រះ
ហឫទ័យរបស់ព្រះអម្ចាស់។ ១៨កុំស្រវឹងស្រាព្រោះ
ស្រាបណ្ដាលឲ្យថោកទាប ផ្ទុយទៅវិញត្រូវឲ្យបាន
ពោរពេញដោយព្រះវិញ្ញាណ។ ១៩ចូរនិយាយគ្នាទៅ
វិញទៅមក ដោយប្រើទំនុកតម្កើងបទសរសើរព្រះជា
ម្ចាស់និងបទចម្រៀងមកពីព្រះវិញ្ញាណ។ ចូរច្រៀង
និងលើកតម្កើងព្រះអម្ចាស់ ឲ្យអស់ពីចិត្ត។ ២០ត្រូវអរ
ព្រះគុណព្រះជាម្ចាស់ ជាព្រះបិតាគ្រប់ពេលវេលា
និងគ្រប់កិច្ចការក្នុងព្រះនាមព្រះយេស៊ូគ្រីស្ដជាព្រះ
អម្ចាស់នៃយើង។

## ទំនាក់ទំនងរវាងស្វាមីភរិយា

២១បងប្អូនដែលកោតខ្លាចព្រះគ្រីស្ត ត្រូវគោរពគ្នា
ទៅវិញទៅមក។

២២បងប្អូនជាស្ត្រីដែលមានស្វាមី ត្រូវគោរពស្វាមី
រៀងៗខ្លួន ដូចគោរពព្រះអម្ចាស់ដែរ ២៣ដ្បិតស្វាមីនាំ
មុខ[ក]ភរិយា ដូចព្រះគ្រីស្តនាំមុខព្រះសហគមន៍*
ហើយជាព្រះសង្គ្រោះរបស់ព្រះសហគមន៍ ដែលជា
ព្រះកាយព្រះអង្គ។ ២៤ហេតុនេះព្រះសហគមន៍
គោរពចុះចូលនឹងព្រះគ្រីស្តយ៉ាងណា ភរិយាក៏ត្រូវ
គោរពចុះចូលនឹងស្វាមីរៀងៗខ្លួន ក្នុងគ្រប់កិច្ចការ
ទាំងអស់យ៉ាងនោះដែរ។

២៥ចំពោះបងប្អូនដែលមានប្រពន្ធវិញ ចូរ
ស្រឡាញ់ភរិយា ដូចព្រះគ្រីស្តបានស្រឡាញ់ព្រះ
សហគមន៍ដែរ ព្រះអង្គបូជាព្រះជន្មរបស់ព្រះអង្គ
ផ្ទាល់សម្រាប់ព្រះសហគមន៍ ២៦ដើម្បីប្រោសឲ្យព្រះ
សហគមន៍បានទៅជាវិសុទ្ធ ទាំងជម្រះឲ្យបានស្អាត
បរិសុទ្ធ ដោយលាងក្នុងទឹក និងដោយសារព្រះបន្ទូ
ល។ ២៧ព្រះអង្គសព្វព្រះហឫទ័យនាំព្រះសហគមន៍
នេះ មកថ្វាយព្រះអង្គផ្ទាល់ ជាព្រះសហគមន៍ដ៏
រុងរឿង ឥតស្លាកស្នាម ឥតជ្រីវជ្រួញ និងឥតខ្ចោះ
ត្រង់ណាឡើយ គឺឲ្យបានទៅជាវិសុទ្ធ* ឥតសៅហ្មុ
ង។ ២៨ដូច្នេះស្វាមីត្រូវស្រឡាញ់ភរិយាឲ្យបានដូច
ស្រឡាញ់រូបកាយរបស់ខ្លួនដែរ។ អ្នកណាស្រឡាញ់
ភរិយា អ្នកនោះស្រឡាញ់ខ្លួនឯង។ ២៩ពុំដែលមាន
នរណាម្នាក់ ស្អប់រូបកាយរបស់ខ្លួនឡើយផ្ទុយទៅវិញ
គេតែងចិញ្ចឹមបីបាច់ថែរក្សារូបកាយនោះដូចព្រះគ្រី
ស្តចិញ្ចឹម បីបាច់ថែរក្សាព្រះសហគមន៍ ៣០ព្រោះ
យើងទាំងអស់គ្នាជាសរីរាង្គនៃ ព្រះកាយរបស់ព្រះអ
ង្គ។ ៣១ហេតុនេះហើយបានជាបុរសត្រូវចាកចេញពី
ឪពុកម្ដាយ ទៅរួមរស់ជាមួយភរិយារបស់ខ្លួន ហើយ
អ្នកទាំងពីរនឹងបានទៅជារូបកាយតែមួយ[ម]៣២គម្រោង
ការដ៏លាក់កំបាំងនេះ មានអត្ថន័យជ្រៅណាស់ ខ្ញុំ
និយាយសេចក្ដីនេះសំដៅលើព្រះគ្រីស្ត និងព្រះសហ
គមន៍តែប៉ុណ្ណោះ។ ៣៣ទោះជាយ៉ាងណាក៏ដោយ បង
ប្អូនម្នាក់ៗត្រូវស្រឡាញ់ភរិយារៀងៗខ្លួនដូច
ស្រឡាញ់ខ្លួនឯង ហើយភរិយាក៏ត្រូវគោរពស្វាមី
របស់ខ្លួនដែរ។

## ទំនាក់ទំនងរវាងឪពុកម្ដាយ និង កូន

១កុមារកុមារី! ចូរស្ដាប់បង្គាប់មាតាបិតា ដោយ
៦យល់ដល់ព្រះអម្ចាស់[យ]ធ្វើដូច្នេះទើបត្រឹមត្រូវ។ ២«
*ចូរគោរពមាតាបិតា* (នេះជាវិន័យទីមួយដែលមាន
ទាំងព្រះបន្ទូលសន្យាជាប់មកជាមួយផង) ៣*ដើម្បី
ឲ្យបានសេចក្ដីសុខ និងមានអាយុវែងនៅលើផែនដី
នេះ»*[រ]។
៤រីឯបងប្អូនដែលជាឪពុកវិញ កុំធ្វើឲ្យកូនរបស់
ខ្លួនមួម៉ៅនោះឡើយ តែត្រូវអប់រំវាដោយពាក្យប្រៀន
ប្រដៅនិងដំបូន្មាន ស្របតាមព្រះអម្ចាស់។

## ទំនាក់ទំនងរវាងទាសករ និង ម្ចាស់

៥បងប្អូនជាទាសករ ចូរស្ដាប់បង្គាប់ម្ចាស់របស់
ខ្លួនក្នុងលោកនេះ ដោយគោរពកោតខ្លាចញាប់ញ័រ
និងដោយចិត្តស្មោះសរ ដូចស្ដាប់បង្គាប់ព្រះគ្រីស្តដែរ
៦មិនត្រូវធ្វើដូច្នេះ ដើម្បីគ្រាន់តែឲ្យម្ចាស់ទាំងនោះ
ឃើញថា បងប្អូនចង់ផ្គាប់ចិត្តមនុស្សឡើយ គឺត្រូវធ្វើ
ដូចជាទាសករព្រះគ្រីស្ត ដែលយកចិត្តទុកដាក់ធ្វើ
តាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ៧ត្រូវបម្រើ
ម្ចាស់ដោយស្ម័គ្រចិត្ត ដូចបម្រើព្រះអម្ចាស់ ពុំមែន
បម្រើមនុស្សទេ ៨ដោយដឹងថាមនុស្សម្នាក់ៗ ទោះជា
អ្នកងារ ឬអ្នកជាក្ដី នឹងទទួលរង្វាន់ពីព្រះអម្ចាស់ តាម
អំពើល្អដែលខ្លួនបានប្រព្រឹត្ត។

៩រីឯបងប្អូនដែលជាម្ចាស់គេវិញ ចូរប្រព្រឹត្ត
ចំពោះទាសកររបស់បងប្អូនបែបនោះដែរ គឺមិនត្រូវ
គំរាមកំហែងគេឡើយ។ តោងដឹងថា ទាំងពួកគេទាំង
បងប្អូន មានម្ចាស់តែមួយនៅស្ថានបរមសុខ* ហើយ
ព្រះអង្គមិនរើសមុខនរណាសោះឡើយ។

## គ្រឿងសស្ត្រាវុធរបស់អ្នកជឿ

១០មួយវិញទៀត ចូរទាញយកកម្លាំងដោយរួម
ជាមួយព្រះអម្ចាស់ និងដោយសារព្រះចេស្ដាដ៏ខ្លាំង
ក្លារបស់ព្រះអង្គ។ ១១ចូរបងប្អូនប្រដាប់ខ្លួនដោយ
គ្រឿងសស្ត្រាវុធទាំងប៉ុន្មានរបស់ព្រះជាម្ចាស់ ដើម្បី
អាចតតាំងនឹងកលល្បិចរបស់មារ* ១២ដ្បិតយើងមិន
មែនតយុទ្ធទល់នឹងមនុស្ស[ល]ទេ គឺតយុទ្ធទល់នឹងវត្ថុ
សក្ដិសិទ្ធិ ទល់នឹងអ្វីៗដែលមានអំណាចទល់នឹងមេ
ត្រួតត្រាក្នុងលោកីយ៍ដ៏ងងឹតនេះ ហើយតយុទ្ធទល់
នឹងឥទ្ធិពលអរូបិយដ៏អាក្រក់ទាំងឡាយ ដែលនៅ
ស្ថានលើដែរ។ ១៣ហេតុនេះ ចូរបងប្អូនប្រើគ្រឿងស
ស្ត្រាវុធទាំងប៉ុន្មានរបស់ព្រះជាម្ចាស់ទៅ ដើម្បីឲ្យបង
ប្អូនអាចតទល់នៅថ្ងៃអពមង្គល ហើយមានជំហរ
រឹងប៉ឹងដដែល ដោយបានប្រើគ្រប់មធ្យោបាយ។
១៤ ដូច្នេះ ចូរមានជំហររឹងប៉ឹងឡើង ចូរយកសេចក្ដីពិត
មកក្រវាត់ចង្កេះ យកសេចក្ដីសុចរិតធ្វើជាអាវក្រោះ
១៥ យកចិត្តប្រុងប្រៀបប្រកាសដំណឹងល្អ អំពីសេចក្ដី
សុខសាន្ត[រ] មកពាក់ជាស្បែកជើង។ ១៦ជាពិសេស ចូរ
យកជំនឿធ្វើជាខែល ដើម្បីឲ្យបងប្អូនអាចពន្លត់ព្រួញ
ភ្លើងទាំងប៉ុន្មានរបស់មារ*កំណាច។ ១៧ចូរទទួលការ
សង្គ្រោះយកមកធ្វើជាមួកដែក និងយកព្រះបន្ទូល
របស់ព្រះជាម្ចាស់ មកធ្វើជាដាវរបស់ព្រះវិញ្ញាណ។
១៨ ចូរអធិស្ឋាន*គ្រប់ពេលវេលា តាមការណែនាំ
របស់ព្រះវិញ្ញាណ ដោយប្រើទាំងពាក្យអធិស្ឋាន ទាំង
ពាក្យអង្វរគ្រប់យ៉ាង ហើយប្រុងស្មារតីទូលអង្វរព្រះ
ជាម្ចាស់ដោយចិត្តព្យាយាមបំផុត សម្រាប់ជនដ៏
វិសុទ្ធ*ទាំងអស់។ ១៩ចូរអង្វរព្រះអង្គសម្រាប់ខ្ញុំផង
សូមព្រះអង្គប្រទានឲ្យខ្ញុំរកបានពាក្យត្រឹមត្រូវ នៅ
ពេលណាខ្ញុំហាមាត់និយាយ សូមប្រទានឲ្យខ្ញុំមាន
ចិត្តអង់អាច នាំគេឲ្យស្គាល់គម្រោងការដ៏លាក់កំបាំង
នៃដំណឹងល្អ* ២០ទោះបីខ្ញុំជាប់ឃុំឃាំងក៏ដោយ ក៏ខ្ញុំ
នៅតែជាទូតនៃដំណឹងល្អនេះដែរ ដូច្នេះសូមទូល
អង្វរព្រះអង្គ ឲ្យខ្ញុំមានចិត្តអង់អាច និយាយតាមដែល
ខ្ញុំត្រូវនិយាយ។

## អវសានកថា

២១លោកទីឃីគូស ជាបងប្អូនដ៏ជាទីស្រឡាញ់
របស់យើង និងជាអ្នកបម្រើដ៏ស្មោះត្រង់របស់ព្រះ
អម្ចាស់ នឹងជម្រាបបងប្អូនអំពីសុខទុក្ខរបស់ខ្ញុំ និង
អំពីកិច្ចការដែលខ្ញុំធ្វើនោះដែរ។ ២២ខ្ញុំចាត់គាត់មករក
បងប្អូន ក្នុងគោលបំណងឲ្យបងប្អូនបានដឹងដំណឹងពី
យើង និងឲ្យគាត់លើកទឹកចិត្តបងប្អូនទៀតផង។

២៣សូមព្រះជាម្ចាស់ជាព្រះបិតា និងព្រះយេស៊ូគ្រី
ស្ដជាព្រះអម្ចាស់ប្រទានសេចក្ដីសុខសាន្ត និងសេចក្ដី
ស្រឡាញ់ ព្រមទាំងជំនឿមកបងប្អូន។ ២៤សូមព្រះ
ជាម្ចាស់ប្រោសប្រណីអស់អ្នក ដែលស្រឡាញ់ព្រះ
យេស៊ូគ្រីស្ដ ជាព្រះអម្ចាស់នៃយើង ដោយឥតមាន
ចិត្តប្រែប្រួលឡើយ។

ក. ឯកសារខ្លះគ្មានសរសេរ«នៅក្រុងអេភេសូ»នេះទេ។.ខ.យើងអាចភ្ជាប់ឃ្លានៅទៅនឹងខ៥ក៏បាន:«ដោយព្រះអង្គមានព្រះហឫទ័យស្រឡាញ់យើង ព្រះអង្គបានតំរូវប៉ា»។

គ.យើងអាចយល់ថាព្រះគ្រីស្ដមានអំណាចខ្លាំងជាងអារុក្ខអារក្ស អ្នកតាខ្មោចបិសាចទេវតាអ្នកតាព្រៃភ្នំក្រំថ្មជាដើមប៉ា។•ឃ.ទំនុកតម្កើង៨.៧។•ង.ឃ្លាដើម:«ក្រុមជំនុំ/ព្រះសហគមន៍បានពោរពេញដោយព្រះអង្គដែលបំពេញគ្រប់ទាំងអស់យ៉ាងពោរពេញ»។យើងអាចបកស្រាយឃ្លានេះតាមរបៀបច្រើនយ៉ាងឧបមាថា«ព្រះគ្រីស្ដគង់នៅក្នុងក្រុមជំនុំ/ព្រះសហគមន៍យ៉ាងពោរពេញឬព្រះអង្គដែលបំពេញពិភពលោកទាំងមូល»ប៉ាជាដើម។•ច.ពាក្យដើម:«មេដែលមានអំណាចនៅលើអាកាស»គឺចង់សំដៅទៅលើមារសាតាំងដែលជាមេលើឥទ្ធិពលអាក្រក់គ្រប់បែបយ៉ាង។

ឆ. ពាក្យដើម:«រងនូវព្រះពិរោធរបស់ព្រះជាម្ចាស់»។•ជ. ឃ្លាដើម«បងប្អូនជាជនបរទេសចំពោះសម្ព័ន្ធមេត្រីនៃ»។•ឈ.គឺសាសន៍កាត់ស្បែក និង សាសន៍មិនកាត់ស្បែក ឬជនជាតិយូដា និង ជនជាតិដទៃ។

សេចក្ដីសុខសាន្តនៃ»។

ញ. អេសាយ៥៧.១៩។•ដ. ពាក្យក្រិក «សម្បត្តិដ៏បរិបូណ៌របស់ព្រះគ្រីស្ត»។

ឋ.ពាក្យដើម «លុតជង្គង់ចុះនៅចំពោះព្រះបិតា»។•ឌ. ពាក្យដើម «មនុស្សខាងក្នុង»។ • ឍ.ពាក្យដើម «ចូរដើរ»។

ណ.ទំនុកតម្កើង ៦៨.១៩។•ត.ឃ្លាដើម«តំបន់នានាដែលនៅក្រោមនៃផែនដី»។យើងអាចបកស្រាយខនេះតាមរបៀបពីរយ៉ាង: ឬមួយព្រះយេស៊ូយាងចុះមកផែនដីដែលនៅខាងក្រោមស្ថានបរមសុខឬព្រះអង្គយាងចុះទៅដល់ស្ថានឃុំមនុស្សស្លាប់។•ថ. យើងអាចបកប្រែម៉្យាងទៀតថា«នៃឲ្យយើងបានពេញវ័យរហូតដល់ធ្វើឲ្យព្រះគ្រីស្តបានបំពេញអ្វីៗទាំងអស់»។•ទ.ឬអស់អ្នកដែលមិនស្គាល់ព្រះជាម្ចាស់។•ធ.ពាក្យដើម«ល្ងង់ខ្លៅ»។ពាក្យនេះមិនមែនចង់និយាយពីជនជាតិដទៃដែលល្ងង់អវិជ្ជានោះទេ គឺចង់សំដៅទៅលើការមិនស្គាល់ព្រះជាម្ចាស់ មិនស្គាល់សេចក្ដីពិត។

ន. សាការី៨.១៦។ • ប.ទំនុកតម្កើង ៤.៥។ • ផ. ពាក្យដើម « យញ្ញបូជាដ៏មានក្លិនឈ្ងុយឈ្ងប់»។

ព. ពាក្យដើម«កូននៃពន្លឺ»។•ភ. ឃ្លាដើម:«ប្ដីជាក្បាលរបស់ភរិយាដូចព្រះគ្រីស្តជាព្រះសិរសារបស់ក្រុមជំនុំ/ព្រះសហគមន៍»។

ម. កំណើតពិភពលោក(លោកុប្បត្តិ) ២.២៤; សូមអានម៉ាថាយ ១៩.៥ដែរ។•យ. ក្នុងឯកសារដើមខ្លះគ្មានពាក្យ «ដោយយល់ដល់ព្រះអម្ចាស់»នេះទេ។ •រ. និក្ខមនំ២០.១២។

ល.ពាក្យដើម «តយុទ្ធជាមួយសាច់និង ឈាម» ដែលសំដៅទៅលើអំណាចឬកម្លាំងរបស់មនុស្ស។ •វ. យើងអាចបកប្រែឃ្លានេះម៉្យាងទៀតថា «យកចិត្តប្រុងប្រៀបដែលបានមកពីដំណឹងល្អនៃ